

# ស្វែងរក ភពភ្លុយតុង

Let's Read
The Asia Foundation



ព្រះអាទិត្យ សម្លឹងឆ្ងាយទៅក្នុងអាកាស ។ ”ភពរបស់ខ្ញុំដូចជាបាត់មួយ?”

ព្រះអាទិត្យ ក៏ឱ្យភពទាំងអស់តម្រង់ជួរ បន្ទាប់មកគេក៏យកវ៉ែនតាមកពាក់ រួចចាប់ផ្តើមរាប់។

”អូ ទេ! តើភពភ្លុយតុងតូចបាត់ទៅណាហើយ ?” ព្រះអាទិត្យ ស្រែក។



ព្រះអាទិត្យ បានយកកាំរស្មីមួយរបស់ខ្លួនទៅប៉ះភពពុធ។ ”តើឯងមានឃើញភពភ្លុយតុងនៅណាទេ?”
ភពពុធ ក៏អេះមាត់រណ្ដៅភ្នំភ្លើងរបស់ខ្លួន ។



”កូនភពភ្លុយតុងខៀវនោះមែន? ខ្ញុំដូចជាមិនបានឃើញគេសោះ។ តើគេទៅណា?” ភពពុធ ឆ្លើយ។



ភពពុធ បានទៅរកភពសុក្រ ហើយសួរថា "តើឯងមានឃើញភពភ្លុយតុងនៅឯណាទេ?"



”តើខ្ញុំធ្វើយ៉ាងម៉េចនឹងដឹងទៅថាកូនភពភ្លុយតុងដ៏ត្រជាក់នោះទៅឯណាទៅ?” ភពសុក្រឆ្លើយ ស្របពេលដែលភ្នំភ្លើងមួយចំនួនរបស់វាផ្ទុះឡើង។



ភពពុធ និងភពសុក្រ ក៏បានទៅរកភពផែនដីហើយសួរថា ”តើឯងមានឃើញភពភ្លុយតុងនៅឯណាទេ?”



រលកសមុទ្របានបោកបក់លើភពផែនដីដោយអន្ទះសា។ ”ភ្លុយតុងដែលមានគន្លងគោចរមិនច្បាស់លាស់នោះមែនទេ?” ភពផែនដី សួរទៅកាន់ភពពុធ និងភពសុក្រ។ ”ខ្ញុំដូចជាមិនបានឃើញគេទេ។”



ភពពុធ ភពសុក្រ និងភពផែនដី បានទៅរកភពអង្គារ ហើយសួរថា ”តើឯងមានឃើញភពភ្លុយតុងនៅឯណាទេ?”



ភពអង្គារ ប្រែជាក្រហមទៅៗ ហើយឆ្លើយទាំងអឹមអៀនថា ”ភ្លុយតុងដែលនៅលើដែនខ្សែក្រវាត់អវកាសខ៉ៃភើនោះមែនទេ? ថ្មីៗនេះ ខ្ញុំមិនដែលឃើញគេនៅទីនោះទេ។”



ភពពុធ ភពសុក្រ ភពផែនដី និងភពអង្គារ បានទៅរកភព
ព្រហស្បតិ៍ ហើយសួរ ”តើឯងបានឃើញភ្លុយតុងនៅឯណាទេ?”



ភពព្រហស្បតិ៍ ក៏បង្វិលខ្លួនយ៉ាងលឿនរកមើលភពភ្លុយតុងនៅគ្រប់ទិសទី។ ”ភ្លុយតុង វិលយឺតណាស់ ខ្ញុំខានឃើញគេមួយរយៈហើយ ។”



ភពពុធ ភពសុក្រ ភពផែនដី ភពអង្គារ និងភពព្រហស្បតិ៍ បាន ទៅរកភពសៅរ៍ ហើយសួរថា ”តើឯងមានឃើញភពភ្លុយតុងនៅឯណាទេ?”



ភពសៅរ៍ ក៏បង្វិលខ្លួនក្នុងខ្សែវ័ណ្ឌ មុននឹងឆ្លើយ ”អូ! ភពភ្លុយតុងកម្សត់ដែលមានទំនាញខ្សោយជាងគេនៅនោះ ខ្ញុំមិនបានឃើញគេទេ។”



ភពពុធ ភពសុក្រ ភពផែនដី ភពអង្គារ ភពព្រហស្បតិ៍ និងភពសៅរ៍ បានទៅរកភពអ៊ុយរ៉ានុស ហើយសួរថា ”តើឯងមានឃើញភពភ្លុយតុងនៅឯណាទេ? ”



ភពអ៊ុយរ៉ានុស ដែលកំពុងតែចង់ចូលគេងនោះ បានស្វាប បណ្ដើរ ពត់ពែនខ្លួនបណ្ដើរ ហើយនិយាយថា ”អត់ឃើញទេ! តែខ្ញុំចង់ឱ្យគេនៅក្បែរនេះ ព្រោះខ្ញុំចូលចិត្តរាប់ព្រះចន្ទទាំងប្រាំ របស់គេ ដើម្បីឱ្យខ្ញុំឆាប់គេងលក់។”



ភពពុធ ភពសុក្រ ភពផែនដី ភពអង្គារ ភពព្រហស្បតិ៍ ភពសៅរ៍ និងភពអ៊ុយរ៉ានុស បានទៅរកភពណិបទូន ដែលកំពុងរងាញ័រញាក់ ហើយក៏សួរថា "តើឯងមានឃើញភពភ្លុយតុងទេ? គេជាអ្នកជិតខាងរបស់ឯង។ ដូចនេះ ឯងច្បាស់ជាដឹងថាគេទៅណា!"



ភពណិបទូន រលាស់ព្រិលចេញពីខ្លួន រួចនិយាយថា ”ខ្ញុំបានឃើញគេរៀបចំបង្វិច។ ភ្លុយតុង ហាក់ស្រងូតស្រងាត់ និងពិបាកចិត្តណាស់។ ប៉ុន្តែ គេមិនបានប្រាប់ខ្ញុំថាគេទៅណា ឬមូលហេតុអ្វីឡើយ ។ ”



ភ្លាមនោះ ភពទាំងអស់បានឮសំឡេងនរណាម្នាក់យំនៅក្បែរនោះ។ ពួកគេក៏ប្រញាប់ទៅមើលថាមានអ្វីកើតឡើង។



ភពភ្លុយតុង កំពុងអង្គុយយំម្នាក់ឯងនៅក្រៅគន្លងរបស់ខ្លួន ។ ភពទាំងអស់សប្បាយចិត្តណាស់ដោយទីបំផុតបានរកឃើញ ភពភ្លុយតុងវិញ! ពួកគេក៏បានសួរនាំពីមូលហេតុដែលភ្លុយតុង បាត់ខ្លួន។

"អ្នកវិទ្យាសាស្រ្តលែងចាត់ទុកខ្ញុំថាជាភពទៀតហើយ ដោយសារខ្ញុំមានទំហំតូច និងមិនអាចយកវត្ថុដែលធំៗ ចេញពី គន្លងរបស់ខ្ញុំបាន។"



ពេលនោះ ព្រះអាទិត្យបានមកដល់ ។
"អត់អីទេ!" ព្រះអាទិត្យនិយាយធ្វើឱ្យបេះដូងភ្លុយតុងដែលកំពុងរងាបានកក់ក្ដៅ។
"ឯងនៅតែជាសមាជិកគ្រួសាររបស់យើងរហូត។ គឺគ្រួសារប្រព័ន្ធព្រះអាទិត្យ!"



ភពទាំងអស់ក៏នាំគ្នាហ៊ោយ៉ាងរីករាយ ”ពួកយើងជាគ្រួសារតែមួយ! គឺគ្រួសារប្រព័ន្ធព្រះអាទិត្យ!”



ចប់

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Finding Pluto*, Published by Asafeer, © Asafeer. Released under CC BY-NC-SA 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC-SA 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc-sa/4.0/
Contributing translators: Somey Chheang, Chan Karukratha TENG, and Chou Chinith